**របាយការណ៍របស់ឯកឧត្តម ម៉ៅ ធនិន អភិបាលនៃគណៈអភិបាលខេត្តកំពត**
**ក្នុងសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំ កន្លងមករបស់រដ្ឋបាលខេត្តកំពត"**
**នៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ**
**នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣**

- *សូមគោរព*...............................................................................................
- ...................................................................................................................
- ...................................................................................................................
- ...................................................................................................................

ថ្ងៃនេះជាទិវាប្រកបដោយនក្ខត្តឫក្សដ៏វិសេសវិសាលបំផុតដែលរដ្ឋបាលខេត្តកំពត ទទួលបានការអនុញ្ញាតឱ្យចូលរួមក្នុងសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំ កន្លងមករបស់រដ្ឋបាលរាជធានី ខេត្ត ប្រចាំឆ្នាំ២០២៣ នាពេលនេះ។ ខ្ញុំសូមការអនុញ្ញាត ធ្វើការបង្ហាញអំពីស្ថានភាពភូមិសាស្ត្រ សក្តានុពល សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងរយៈពេល៥ឆ្នាំ និងទិសដៅអនុវត្តបន្តរបស់រដ្ឋបាលខេត្តកំពត ដូចខាងក្រោម៖

**អំពីស្ថានភាពភូមិសាស្ត្រ៖** ខេត្តកំពត ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ មានព្រំប្រទល់៖ ខាងជើងជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងកើតជាប់នឹងខេត្តតាកែវ ខាងត្បូងជាប់នឹងខេត្តកែបនិងប្រទេសវៀតណាម ខាងលិចជាប់នឹងខេត្តព្រះសីហនុ និងឈូងសមុទ្រថៃឡង់ត៏ មានផ្ទៃដីសរុប ៤.៨៧៣,២ គ.ម$^{២}$ មាន ៩ក្រុង ស្រុក ៩៣ឃុំ សង្កាត់ និង៤៩១ ភូមិ ក្នុងនោះ២/៣ជាព្រៃភ្នំ និងសមុទ្រ។ មានប្រជាពលរដ្ឋសរុប ៦៩៦.៥៨៣នាក់ (ស្រី៣៥៣.២៨៩នាក់) ស្មើនឹង ១៦៥.១៧១ គ្រួសារ អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន ៤២១.១១៨ នាក់ ស្រី ២២៥.៣៣៧ នាក់។ អត្រានៃភាពក្រីក្រ១៤,៨% ចំណូលប្រជាពលរដ្ឋក្នុង១នាក់ប្រចាំឆ្នាំ ១.៨១៥ដុល្លារ។ ខេត្តកំពតជាប់នឹងតំបន់ឆ្នេរសមុទ្រ ជាតារារៈទិសនិរតី មានចំងាយ ១៤៨ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ភ្ជាប់ដោយផ្លូវជាតិលេខ៣ និងមានផ្លូវជាតិលេខ៤១ លេខ៣១ លេខ៣២ លេខ៣៣ លេខ៤៣ ព្រមទាំងមានផ្លូវរថភ្លើង១ខ្សែ ភ្ជាប់ពីភ្នំពេញមកកាន់ខេត្តកំពត និងទៅខេត្តព្រះសីហនុ។

ក្រោមការដឹកនាំប្រកបដោយគិតិបណ្ឌិតដ៏ឈ្លាសវៃបំផុត និងចក្ខុវិស័យច្បាស់លាស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងជានិមិត្តរូបនៃសន្តិភាព សម្តេចតេជោនាយករដ្ឋមន្ត្រីបានលះបង់គ្រប់យ៉ាងដោយមិនគិតពីអាយុជីវិត ដើម្បីនាំមកនូវសន្តិភាព និងស្ថេរភាពនយោបាយជូនជាតិមាតុភូមិ តាមរយៈនយោបាយ ឈ្នះ ឈ្នះ។ សន្តិភាព ដែលយើងទាំងអស់គ្នាទទួលបាននៅពេលនេះ គឺពិតជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុត ដែលផ្តល់ឱកាសឱ្យកម្ពុជា អាចស្តារ និងអភិវឌ្ឍន៍ប្រទេសបានរីកចម្រើនឡើងវិញគ្រប់វិស័យ។ ដោយអនុវត្តន៍តាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់

កាលទី៤ និងផែនការអភិវឌ្ឍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់រដ្ឋបាលខេត្តកំពត រួមជាមួយនឹងយន្តការផ្សេងៗជាច្រើនទៀត ដូចជាក្រុមការងាររាជរដ្ឋាភិបាល វិស័យគាំពារសង្គម និងដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ លើគ្រប់វិស័យនៅក្នុងខេត្តមានការអភិវឌ្ឍន៍ ដែលទទួលបានសមិទ្ធផលសំខាន់ៗជាច្រើន បានធ្វើឱ្យប្រជាជនខេត្តកំពតមានការពេញចិត្ត និងទទួលបាននូវការកាត់បន្ថយភាពក្រីក្របន្ថែមទៀត។

**១.អំពីសក្តានុពលសំខាន់ៗរបស់ខេត្តកំពត៖**

ខេត្តកំពត មានសក្តានុពលធនធានធម្មជាតិសំបូរបែបរួមមាន៖ ដីស្រែ ឆ្នេរសមុទ្រ ស្ទឹង ព្រែក កោះ ឧទ្យានជាតិ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ធនធានជលផល រ៉ែ និងអាគារបេតិកភណ្ឌ សម្រាប់ការអភិវឌ្ឍពហុវិស័យដូចជា វិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍។ ខេត្តមានផ្ទៃដី បង្កបង្កើនផល ១១៥.៥០០ ហិកតា (មួយរយដប់ប្រាំពាន់ ប្រាំរយហិកតា) ដែលសំបូរទៅដោយដំណាំស្រូវ ម្រេច ដូង ធុរេន ចេក -ល-។ ប្រព័ន្ធគមនាគមន៍ មានផ្លូវជាតិលេខ៣ លេខ៤១ លេខ៤៣ លេខ៣១ លេខ៣២ លេខ៣៣ និងផ្លូវរថភ្លើង ១ខ្សែ តភ្ជាប់ពីភ្នំពេញ ទៅកំពត និងពីកំពត ទៅព្រះសីហនុ ។ ឆ្នេរសមុទ្រមានប្រវែង ៦៥,៦ គីឡូម៉ែត្រ មានព្រែកចំនួន ១៣ព្រែក ព្រៃកោងកាង ១.៩៥៦ហិកតា ស្មៅសមុទ្រ ៨.៤៣៥ហិកតា ផ្កាថ្ម ៩៥៣ហិកតា មានឧទ្យានជាតិព្រះមុន្នីវង្សបូកគោ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ ៣៤កន្លែង ។ រ៉ែស៊ីម៉ង់ត៍ មានរោងចក្រផលិតស៊ីម៉ង់ត៍ចំនួន ៤កន្លែង មានកំពង់ផែសមុទ្រធំៗចំនួន ៦កន្លែង។ ធនធានជលផល មានត្រីសមុទ្រ ៥២០ប្រភេទ ស្រែអំបិលមាន ផ្ទៃដី ៣.៥៤៣,៦៩ ហិកតា វារីអគ្គិសនី ផលិតថាមពលបាន ១៩៤,១មេហ្គាវ៉ាត់ មានច្រកទ្វារអន្តរជាតិ និងច្រកទ្វេរភាគី និងក្រុមហ៊ុនវិនិយោគតំបន់ឆ្នេរចំនួន ១៦ ។

**២.អំពីសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២)៖**

ក.ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ក្នុងរយៈពេល៥ឆ្នាំនេះ ផ្លូវបានសាងសង់មានប្រវែងសរុប ១.៥១៨,៧២ គីឡូម៉ែត្រ (មួយពាន់ប្រាំរយដប់ប្រាំបី ក្បៀស ចិតសិបពីរ គីឡូម៉ែត្រ) និងស្ពានបេតុងចំនួន ៦កន្លែង ក្នុងនោះផ្លូវមាន ៖ **ផ្លូវក្រាលកៅស៊ូ** មានប្រវែង ១៥៨,០៩ គីឡូម៉ែត្រ (មួយរយហាសិបប្រាំបី ក្បៀសប្រាំបួនគីឡូម៉ែត្រ) សាងសង់ដោយ (មន្ទីរសាធារណៈការមានប្រវែង ៥៨,៨៤០គីឡូម៉ែត្រ, មន្ទីរអភិវឌ្ឍន៍ជនបទ មានប្រវែង ៩៩,២៥២ គីឡូម៉ែត្រ, សាលាខេត្ត មានប្រវែង ២,៤៧៥គីឡូម៉ែត្រ)។ **ផ្លូវបេតុងសរសៃដែក** មានប្រវែង ៧៨,៩០០ គីឡូម៉ែត្រ (ចិតសិបប្រាំបី ក្បៀសប្រាំបួនរយ គីឡូម៉ែត្រ) សាងសង់ដោយ (មន្ទីរសាធារណៈការមានប្រវែង ២៨០ម៉ែត្រ, សាលាខេត្ត មានប្រវែង ១២,៨០៨ គីឡូម៉ែត្រ, ក្រុង-ស្រុក មានប្រវែង ៥៥,៨៧៣គីឡូម៉ែត្រ)។ **ផ្លូវក្រាលគ្រួសក្រហម** ១.០៣៧,៥៧ គីឡូម៉ែត្រ (មួយពាន់ សាមសិបប្រាំពីរ ក្បៀសហាសិបប្រាំពីរ គីឡូម៉ែត្រ) សាងសង់ដោយ (មន្ទីរអភិវឌ្ឍន៍ជនបទ មានប្រវែង ១០២,៩៥៦ គីឡូម៉ែត្រ, សាលាខេត្ត មានប្រវែង ១២,៨០៨ គីឡូម៉ែត្រ, ក្រុង-ស្រុក មានប្រវែង៩២១,៨០៣

គីឡូម៉ែត្រ)។ **ផ្លូវជីស** ២៤៤,១៦០ គីឡូម៉ែត្រ (ពីររយសែសិបបួន ក្បៀសមួយរយហុកសិបគីឡូម៉ែត្រ) សាងសង់ដោយ (មន្ទីរសាធារណៈការ មានប្រវែង ១០,១០០ គីឡូម៉ែត្រ, មន្ទីរអភិវឌ្ឍន៍ជនបទ ១៧២,៤២១ គីឡូម៉ែត្រ, ក្រុង-ស្រុក មានប្រវែង ៦១,៦៤១គីឡូម៉ែត្រ)។ ស្ពានបេតុងចំនួន ៦កន្លែង សាងសង់ដោយ (មន្ទីរសាធារណៈការ មានចំនួន ៣កន្លែង, មន្ទីរអភិវឌ្ឍន៍ជនបទ ១កន្លែង, ក្រុង-ស្រុក មានចំនួន ២កន្លែង)។

**បានជីក ស្តារប្រព័ន្ធស្រោចស្រប** រួមមាន៖ ប្រឡាយទឹកមានប្រវែង ៦៧៨,៥៣ គីឡូម៉ែត្រ (ប្រាំមួយរយចិតសិបប្រាំបី ក្បៀសហាសិបបីគីឡូម៉ែត្រ) សាងសង់ដោយមន្ទីរធនធានទឹក និងឧតុនិយម មានចំនួន ៦១៤,៦៧គីឡូម៉ែត្រ, ក្រុង-ស្រុក មានចំនួន ៦៣,៨៦គីឡូម៉ែត្រ។ ទំនប់ទឹក ១៣,៦៨ គីឡូម៉ែត្រ សាងសង់ដោយមន្ទីរធនធានទឹកមានប្រវែង ១១,៦១គីឡូម៉ែត្រ, ក្រុង-ស្រុកមានប្រវែង ២,០៧ គីឡូម៉ែត្រ សំណង់ទ្វារទឹក និងស្នាក់ទឹក សាងសង់ដោយមន្ទីរធនធានទឹក ៣៦៨កន្លែង ទំនប់បង្វៀរ ៣កន្លែង និងមានស្ថានីយ៍ឧតុនិយម និងជលសាស្ត្រ ៦កន្លែង ព្រមទាំងមានព្រែកចំនួន១៣។

**អំពីសំណង់អគារ**

សំណង់អាគារសម្រាប់ផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈ ជូនប្រពលរដ្ឋមានចំនួនគ្រប់គ្រាន់ នៅតាមទីតាំងផ្តល់សេវា តាំងទីប្រជុំជន និងជនបទ។ នៅក្នុងរយៈពេល៥ឆ្នាំនេះ សំណង់អាគារសំខាន់ៗ ដែលបានសាងសង់ថ្មីមានចំនួន ១៣៣ អគារ (សាលាក្រុង ស្រុក ២, ការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ៤, សាលាឃុំចំនួន ២៧ មណ្ឌលសុខភាព ៥ ប៉ុស្តិ៍រដ្ឋបាល ៦៤ ។ គិតត្រឹមឆ្នាំ២០២២ អាគារ សិក្សាមានចំនួន ៧១៥ខ្នង មានចំនួន ៨.២៣៨ បន្ទប់ (**អំណោយសម្តេចតេជោ ចំនួន ៥១៣ ខ្នង** ថវិកា រដ្ឋ ២០២ខ្នង) កសាងថ្មីចំនួន ៣១ខ្នង ស្មើនឹង ២៣៣បន្ទប់ ។ ឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន តំណាង រា ស្ត្រមណ្ឌលកំពត បានឧបត្ថម្ភដល់សិស្សក្រីក្រ និងសិស្សប្រឡងជាប់ និងសិស្សបាននិទ្ទេស A ក្នុងឆ្នាំ ២០២២ សរុបថវិកាចំនួន ៥១៨.៩៥០.០០០ រៀល និងម៉ូតូDream2023 ចំនួន ៣៧គ្រឿង ស្មើនឹង ៧៨.៨១០ ដុល្លារ ។ សណ្ឋាគារ ផ្ទះសំណាក់ អគារផ្សេងៗ ដែលមានកម្ពស់៥ជាន់ឡើង បានសាងសង់ ក្នុងរយៈពេល៥ឆ្នាំ មានចំនួន ៤៤ កន្លែង ។ រោងចក្រសហគ្រាសសរុបក្នុងខេត្ត មានចំនួន ៤៤២ ក្នុងនោះ មានរោងចក្រស៊ីម៉ង់ត៍ ៤ កន្លែង (មានកម្មករ និយោជិកធ្វើការសរុប ២៣.៨៩៦នាក់)។

**អំពីស្ថានីយទឹកស្អាត និងការផលិតអំបិល៖** ស្ថានីយ៍ទឹកស្អាតមានចំនួន១៩ មានសមត្ថភាពផលិត បានចំនួន ១៧.៩២១.៥០០ ម$^{៣}$ (ដប់ប្រាំពីរលាន ប្រាំបួនរយម្ភៃមួយពាន់ ប្រាំរយម៉ែត្រគូប) ក្នុង១ឆ្នាំ គ្របដណ្តប់គ្រប់ក្រុង ស្រុក ឃុំទីប្រជុំជន សរុបមានចំនួន ៧៣ ឃុំ-សង្កាត់ / ៩៣ ឃុំ សង្កាត់។ អំបិល ក្នុងរយៈពេល៥ឆ្នាំនេះផលិតបានចំនួន ២០២.៥៣០ តោន (ពីររយពីរពាន់ ប្រាំរយសាមសិប តោន) និង អំបិលនាំចូលចំនួន ៣៨.១៧៣ តោន (សាមសិបប្រាំបីពាន់ មួយចិតសិបបី តោន) នៅក្នុងឆ្នាំ ២០១៨ ឆ្នាំ២០១៩ និង២០២២ អាកាសធាតុមិនអំណោយផលដល់ការផលិតអំបិលទេ។

**ការងារអគ្គិសនី៖** ខេត្តកំពតមានទំនប់វារីអគ្គិសនី អគ្គិសនីកម្ពុជាកំពត និងមានសេវាករចែកចាយចំនួន ៨សេវាករ។ គិតមកដល់ឆ្នាំ២០២២នេះ បានតបណ្តាញគ្របដណ្តប់ទូទាំងខេត្តបានចំនួន ៤៨៨ ភូមិ នៅសល់ ៣ភូមិទៀត គិតជាភាគរយស្មើនឹង ៩៩,៣៨ %។

**កំពង់ផែសមុទ្រ** មានកំពង់ផែធំៗចំនួន៥ ក្នុងនោះ ១ជាកំពង់ផែទេសចរណ៍អន្តរជាតិ, ក្រៅពីកំពង់ផែធំៗទាំងនោះ យើងមានកំពង់ផែតូចៗមួយចំនួនទៀត។

**ការរៀបចំសួនច្បារ ឆ្នេរសមុទ្រ**: ខេត្តបានរៀបចំសួនច្បារឡើងវិញដោយក្រាលម៉ាបសុទ្ធតាមបណ្តោយព្រែក ហើយបានកសាងឆ្នេរខ្សាច់ប្រវែង ២០០០ ម៉ែត្រ នៅតំបន់កោះស្មៅ កំពុងដំណើរការសាងសង់ឆ្នេរចំនួន៤បន្តទៀត និងមានបំពាក់បង្គោលភ្លើងបំភ្លឺនៅតាមទីសាធារណៈ។ បានរៀបចំប្រព័ន្ធពិពិធកម្មទឹកកខ្វក់ ៣០០០ម៉ែត្រ និងបានរៀបចំស្តារដោយធ្វើប្រឡាយបេតុង ដើម្បីរំដោះទឹកស្អុយនៅទីប្រជុំជនក្នុងក្រុង ប្រវែង ៧៥០ម៉ែត្រ ដោយគម្រោង ADB ។

## ខ. វិស័យកសិកម្ម

ផ្ទៃដីបង្កបង្កើនផលមានចំនួន ១១៥.៥០០ហិកតា ផលិតស្រូវក្នុងរយៈពេល៥ឆ្នាំបានចំនួន ២.២៨៥.៧១០តោន គិតជាធម្យមភាគក្នុង១ឆ្នាំ ៤៥៧.១៤២តោន។ មានដំណាំឧស្សាហកម្ម ចេក និងម្រេចនាំចេញទៅក្រៅប្រទេស ក្រៅពីនេះមានដំណាំរួមផ្សំជាច្រើនទៀតដូចជា ម្រេច ទុរេន ដូង ។ល។ ត្រីសមុទ្រមាន ៥២០ប្រភេទ មានសហគមន៍នេសាទមានចំនួន ៩ ផលនេសាទសមុទ្ររកបានចំនួន ១០៦.២២៤តោន គិតជាធម្យមភាគក្នុង១ឆ្នាំ ២១.២៤៥តោន។ មានកសិដ្ឋានចិញ្ចឹមជ្រូក និងមាន់ព្រមទាំងផលិតសាច់សត្វផ្គត់ផ្គង់ក្នុងប្រទេស និងមានផែនការនាំចេញទៅប្រទេសម៉ាឡេស៊ី និងប្រទេសចិន។

## គ. ការងារទេសចរណ៍

ក្នុងខេត្តមានរមណីយដ្ឋាន និងគោលដៅទេសចរណ៍ចំនួន ៣៤កន្លែង ភ្ញៀវទេសចរមកកម្សាន្តក្នុងខេត្តកំពតក្នុងរយៈពេល៥ឆ្នាំនេះឃើញថាកើនឡើងយ៉ាងខ្លាំងឆ្នាំ២០២២ បើប្រៀបធៀបជាមួយឆ្នាំ ២០២១ មានការកើនឡើងចំនួន ៩៥២.៤០០នាក់ ។

## ឃ. ការងារចុះបញ្ជីដីធ្លី

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ការចុះបញ្ជីដីធ្លីចេញបណ្ណជូនដល់ប្រជាពលរដ្ឋបានចំនួន៥៧.៨៩១ បណ្ណ បូកយោងគិតចាប់ពីឆ្នាំ២០០៣ រហូតមកត្រឹមឆ្នាំ២០២២ មានចំនួន ៥៦២.០៧៤ បណ្ណ គិតជាភាគរយស្មើនឹង ៧០,២៦% នៃក្បាលដីប៉ាន់ស្មានទូទាំងខេត្តសរុបចំនួន ៨០០.០០០ ក្បាលដី។

## ង. ការរៀបចំវេទិការសាធារណៈ និងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ

វេទិកាសាធារណៈក្រុមប្រឹក្សាខេត្តបានធ្វើមួយឆ្នាំម្តង និងវេទិកាក្រុមការងាររាជរដ្ឋាភិបាល ដែលមាន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ជាប្រធានក្រុមការងារ បានដាក់ចេញនូវផែនការវេទិកាសាធារណៈប្រចាំឆ្នាំ មួយខែ១ដង ក្នុងមួយឃុំ-សង្កាត់ ជាលទ្ធផលក្នុងរយៈពេល៥ឆ្នាំ បានធ្វើវេទិកាសាធារណៈចំនួន ២.៨៧៨លើក មានការចូលរួមពីប្រជាពលរដ្ឋចំនួន ១៤៦.៤៤៩នាក់ បានដោះស្រាយជូនប្រជាពលរដ្ឋ ៦.៧៩៦ករណី និងបានឧបត្ថម្ភថវិកាដែលបានពីសប្បុរសជន និងក្រុមការងារជូនពលរដ្ឋក្រីក្រចំនួន ៣៦.៤៤៨.៤៨៣.០០០រៀល( សាមសិបប្រាំមួយពាន់លាន បួនរយសែសិបប្រាំបី បួនរយប៉ែតសិបបីពាន់រៀល )។

**ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ** គិតចាប់ពីថ្ងៃទី១៨ តុលា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ម៉ៅ ធនិន** អភិបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុក បានសម្របសម្រួលដោះស្រាយបញ្ហាបណ្តឹង និងសំណូមពរផ្សេងៗជូនប្រជាពលរដ្ឋបានចំនួនសរុប ១.១៥៨ករណី បានឧបត្ថម្ភថវិកា និងអង្ករជូនពលរដ្ឋក្រីក្របានចំនួន ១៥.៧៨០នាក់ ស្មើនឹង ១.៥៧៨គ្រួសារ។

## ច. វិស័យគាំពារសង្គម

សម្តេចតេជោនាយករដ្ឋមន្ត្រីបានយកចិត្តទុកដាក់កខ្ពស់បំផុតចំពោះសុខមាលភាព និងអាយុជីវិតប្រជាជនក្រៅពីផ្តល់ថវិកាជាច្រើន សម្រាប់ជួយដល់ប្រជាជនក្រីក្រ កុមារក្រោមអាយុ២ឆ្នាំ ស្ត្រីមានផ្ទៃពោះ និវត្តជន និងអតីតយុទ្ធជន។ សម្តេចបានបញ្ចេញសាច់ប្រាក់បន្ថែមជាច្រើនក្នុងការប្រយុទ្ធប្រឆាំង និងជំងឺកូវីដ-១៩ ព្រមទាំងដាក់ចេញនូវយន្តការដ៏មុតស្រួចដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានចាក់វ៉ាក់សាំងជូនប្រជាជនដោយឥតគិតថ្លៃ ឧបត្ថម្ភសាច់ប្រាក់ជួយដល់គ្រួសារកើតជំងឺកូវីដ-១៩ សពស្លាប់ដោយសារជំងឺកូវីដ-១៩ គ្រួសារក្រីក្រប្រភេទ១ ប្រភេទ២ និងគ្រួសារដែលរងហានីភ័យអស់រាប់ពាន់លានដុល្លារ។ ជាក់ស្តែង ខេត្តកំពតប្រជាជនក្រីក្រទទួលបានថវិកាឧបត្ថម្ភសរុបចំនួន ១៧២.១៥៣នាក់ និង ៧៤.៥៩៨គ្រួសារ ហើយបានចំណាយថវិកាអស់ ៤១៧.០៨៩.៧៣៤.០០០រៀល (បួនរយដប់ប្រាំពីរពាន់លាន ប៉ែតសិបប្រាំបួន ប្រាំពីររយសាមសិបបួនពាន់រៀល) ប្រមាណ ១០៤.២៧២.៤៣៣ដុល្លារ (មួយរយបួនលាន ពីររយចិតសិបពីរពាន់បួនរយសាមសិបបីដុល្លារ) ក្នុងនោះ៖ ការងារមនុស្សធម៌ របស់សាខាកាកបាទក្រហមចំនួន ២៨.០៣៩គ្រួសារ ស្មើនិង ៤.២៧៥.២៦៨.០០០រៀល (បួនពាន់លាន ពីររយចិតសិបប្រាំ ពីររយហុកសិបប្រាំបីពាន់រៀល) មូលនិធិសមធម៌សុខាភិបាលមានចំនួន ៦.៧៩៦.៦១៧.០០០រៀល(ប្រាំមួយពាន់លាន ប្រាំពីររយកៅសិបប្រាំមួយ ប្រាំមួយរយដប់ប្រាំពីរពាន់រៀល) មូលនិធិជាតិជំនួយសង្គម របស់សង្គមកិច្ច មានចំនួន ៣៥២.៣៦០.៣៣៥.០០០រៀល (បីរយហាសិបពីរពាន់លាន បីរយហុកសិប បីរយសាមសិបប្រាំពាន់រៀល) សប្បុរសជន មន្ត្រីរាជការ ថ្នាក់ដឹកនាំខេត្ត ឧបត្ថម្ភជូនជនក្រីក្រចំនួន ១៧.២០៩.០៣១.០០០រៀល (ដប់ប្រាំពីរពាន់លាន ពីររយប្រាំបួន សាមសិបមួយពាន់រៀល) សប្បុរសជន និងក្រុមការងាររដ្ឋាភិបាល(ក្រសួង

ខេត្ត) ជួយឧបត្ថម្ភ និងដោះស្រាយបញ្ហាសំណូមពរ ជូនប្រជាពលរដ្ឋចំនួន ៣៦.៤៤៨.៤៨៣.០០០រៀល (សាមសិបប្រាំមួយពាន់លាន បួនរយសែសិបប្រាំបី បួនរយប៉ែតសិបបីពាន់រៀល)។

**ឆ. ការងារសណ្តាប់ធ្នាប់សាធារណៈ:**

គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រោមការដឹកនាំ បញ្ជាដោយផ្ទាល់ពីសំណាក់ ឯកឧត្តម អភិបាលខេត្ត ដោយមានការចូលរួមពីកងកម្លាំង អាជ្ញាធរក្រុង ស្រុក បានយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំ ប្រតិភូរាជរដ្ឋាភិបាល ភ្ញៀវជាតិ អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋ ទទួលបាននូវលទ្ធផលល្អប្រសើរ ដោយពុំមានហេតុការណ៍ណាមួយកើតឡើងគួរឱ្យកត់សម្គាល់ឡើយ ។ ករណីបទល្មើសមានការថយចុះ ហើយរាល់សកម្មភាពបទល្មើសដែលកើតមានឡើង កម្លាំងអាជ្ញាធរ បានធ្វើការបង្ក្រាបទាន់ពេល។ លទ្ធផលល្អប្រសើរទាំងនេះបានបង្ហាញនៅក្នុងចលនាប្រឡងប្រណាំងភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ។ ជាក់ស្តែងចលនាប្រឡងប្រណាំងភូមិឃុំ សង្កាត់ មានសុវត្ថិភាព ខេត្តកំពត បានជាប់ចំណាត់ថ្នាក់ ទាំង៩៣/៩៣ ឃុំ សង្កាត់ ក្នុងនោះ ចំណាត់ថ្នាក់លេខ១ មានចំនួន ៨២ឃុំ សង្កាត់ ចំណាត់ថ្នាក់លេខ២ មានចំនួន ១១ឃុំ សង្កាត់ ។ **ការងារអត្តសញ្ញាណកម្ម៖** បានផ្តល់អត្តសញ្ញាណប័ណ្ណគំរូថ្មីចំនួន ៩៣.៣១០សន្លឹក សៀវភៅស្នាក់នៅ (ក២) ៤៤.៣៧៤ ក្បាល សៀវភៅគ្រួសារ(ក៤) ២០.១៩៨ ក្បាល ។

## ៣.ទិសដៅការងារបន្ត៖

- បន្តរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្ត
- បន្តរៀបចំកែលម្អសួនច្បារ ឆ្នេរតាមដងព្រែកកំពត និងឆ្នេរសមុទ្រ
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធតាមទីប្រជុំជន និងនៅទីជនបទ
- បន្តចុះរៀបចំវេទិកាសាធារណៈ ដើម្បីប្រមូលព័ត៌មាន បញ្ហា តម្រូវការ និងដំណោះស្រាយជូនប្រជាពលរដ្ឋ
- បន្តដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ជូនប្រជាពលរដ្ឋ
- បន្តយកចិត្តទុកដាក់រក្សាសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ
- បន្តយកចិត្តទុកដាក់លើកកម្ពស់ការផ្តល់សេវាទាំងរដ្ឋបាល សេវាសាធារណៈ សេវាតម្រូវការចាំបាច់នានា ដើម្បីចូលរួមសុខុមាលភាព និងជីវភាពរស់នៅ របស់ប្រជាជន........។

ជាទីបញ្ចប់ សូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងអង្គពិធីនេះ ប្រកបតែពុទ្ធិពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ!*